# គំរូនៃលទ្ធិប្រជាធិបតេយ្យពីសម័យពុទ្ធកាល

**"ព្រះពុទ្ធសាសនាជាគំរូនៃលទ្ធិប្រជាធិបតេយ្យដែលចាស់ជាងគេបំផុតក្នុងលោក មានវិធីសាស្ត្រនិង គោលការណ៍ដ៏ទាន់សម័យរហូតមកដល់បច្ចុប្បន្ននេះ ។"**

យើងគួរតែនាំគ្នាពិចារណាជាមុនសិនថា ពាក្យថាប្រជាធិបតេយ្យដែលយើងប្រែពីភាសាអង់គ្លេសថា Democracy នោះបានន័យថាដូចម្តេច? រួចហើយសឹមនាំគ្នាពិចារណាតទៅទៀតថា ព្រះពុទ្ធសាសនាជាគំរូនៃលទ្ធិប្រជាធិបតេយ្យដ៏មានចំណាស់បំផុតក្នុងលោក មានវិធីសាស្ត្រនិងគោលការណ៍ដ៏ទាន់សម័យយ៉ាងដូចម្តេច?

**ប្រជាធិបតេយ្យ** យើងអាចកាត់បទចេញជាពីរយ៉ាងគឺ **ប្រជា** និង **អធិបតេយ្យ** ប្រែថាការយកប្រជាជនជាធំ ជាពាក្យដែលប្រៀបធៀបទៅនឹងភាសាអង់គ្លេស គឺមានន័យប្រហាក់ប្រហែលគ្នា។ ភាសាអង់គ្លេសថា Democracy នោះ ដើមកំណើតពាក្យមកពីភាសាក្រិចថា Demokratia ហើយភាសាក្រិចនេះយើងអាចកាត់ជាពីរបទដូចគ្នាគឺ Demos ប្រែថា ប្រជាជន Kratia ប្រែថា អំណាច។ យើងរួមបទទាំងពីរបញ្ចូលគ្នាមកមានន័យស្មើនឹងភាសាអង់គ្លេសថា People's power ដែលប្រែថា អំណាចរបស់ប្រជាជន ។

ពាក្យថាប្រជាធិបតេយ្យត្រូវបានគេផ្តល់និយមន័យខ្លីៗថា **"ប្រជាធិបតេយ្យ គឺជាទម្រង់ ឬជាប្រព័ន្ធគ្រប់គ្រងដែលជនគ្រប់ជាន់ថ្នាក់មានអំណាចដ៏ខ្ពង់ខ្ពស់ ហើយប្រើប្រាស់អំណាចនោះតាមរយៈអ្នកតំណាងរបស់ខ្លួន ។"** (Democracy is a form of government in which the people retain supreme power and exercise their power through representatives.)

ប្រទេសក្រិចមានឈ្មោះថាជាកន្លែងផ្តល់កំណើតដល់លទ្ធិប្រជាធិបតេយ្យក្នុងពិភពលោកយើងនេះ ព្រោះហេតុនោះទើបពាក្យអង់គ្លេសដែលមានន័យត្រូវនឹងពាក្យថាប្រជាធិបតេយ្យជាពាក្យដែលមានឫសគល់មកពីភាសាក្រិច ។

កាលដែលស្រាវជ្រាវស្វែងយល់ពីប្រវត្តិសាស្ត្រថា តើប្រជាធិបតេយ្យរបស់ក្រិច ចាប់ផ្តើមឡើងពីកាលណាមក? យើងនឹងជួបនូវចំលើយថា អ្នកប្រវត្តិសាស្ត្រនៅតែប្រកែកគ្នាមិនចេះដាច់ស្រេចចំពោះរឿងនេះ ។ អ្នកខ្លះនិយាយថា សូឡូន (Solon) ដែលកើតប្រហែល ៦៣៨ មុនគ្រិស្តសករាជ ដែលជារយៈពេលប្រកិត

គ្មានឹងព្រះសម្មាសម្ពុទ្ធនោះ ឈ្មោះថាជាបិតាប្រជាធិបតេយ្យរបស់ក្រិច ។ អ្នកខ្លះនិយាយថា ឃ្លិសថេនីស (Cleisthenes) ដែលកើតក្រោយ Solon ប្រហែលមួយរយឆ្នាំឯណោះទេដែលគួរនឹងបានឈ្មោះថាជាបិតាប្រជាធិបតេយ្យរបស់ក្រិច ។ ប៉ុន្តែអំឡុងពេលដែលអ្នកប្រវត្តិសាស្ត្រភាគច្រើនអះអាងថា ប្រជាធិបតេយ្យរបស់ក្រិចរីកចំរើនខ្លាំង គឺក្នុងសម័យរបស់ប៉េរិឃ្លីស (Pericles) ដែលជាសម័យតែមួយជាមួយនឹង សូក្រាត ( Socrates) និង ប្លាតូ (Plato) អ្នកប្រាជ្ញដ៏ល្បីល្បាញរបស់ក្រិច ដែលជារយៈពេលបន្តបន្ទាប់ គ្នាពីសម័យរបស់ឃ្លិសថេនីស មិនដល់មួយរយឆ្នាំផង ។

ដូច្នេះយើងគប្បីសរុបសេចក្តីជាបឋមសិនថា បើនឹងស្វែងយល់ពីកំណើតប្រជាធិបតេយ្យរបស់ក្រិច យើងអាចមើលបាន៣ សម័យកាលដែលមានពេលប្រកិតគ្នាឬឃ្លាតពីគ្នាមិនដល់មួយរយឆ្នាំផងគឺៈ

១-សម័យកាលដំបូងកាលពី ៥៩៤ ឆ្នាំមុនគ្រិសសករាជ ពេលដែលសូឡូនបានកែប្រែរដ្ឋធម្មនុញ្ញរបស់ក្រិច ដែលជាពេលដំបូងបង្អស់ដែលមានសភាប្រជាជន ។

២-រយៈពេលបន្ទាប់មក កាលពី ៥០៩ ឆ្នាំមុនគ្រិស្តសករាជ ពេលដែលឃ្លិសថេនីស កែប្រែរដ្ឋធម្មនុញ្ញរបស់ក្រិចម្តងទៀត ដោយផ្តល់សិទ្ធិសេរីភាពដល់ប្រជាជនកាន់តែខ្លាំងឡើង ។

៣-រយៈពេលបន្ទាប់មកទៀត កាលពី ៤៦១ ឆ្នាំមុនគ្រិស្តសករាជ ដែលចាត់ជាកាលសម័យដ៏រុងរឿងរបស់ក្រិច ប៉េរិឃ្លីស ដែលប្រកាន់គោលការណ៍លទ្ធិប្រជាធិបតេយ្យតាមបែបឃ្លិសថេនីស លើកស្ទួយអោយលទ្ធិប្រជាធិបតេយ្យតាមបែបឃ្លិសថេនីស បានរីកចំរើនខ្លាំងក្លាជាទីបំផុតក្នុងសម័យនោះ ។

ទាំង៣សម័យកាលនេះ មានវេលាបន្តបន្ទាប់និងប្រកិតគ្នា រយៈពេលបីរយឆ្នាំដំបូងគឺជារយៈពេលប្រហាក់ប្រហែលទៅនឹងសម័យពុទ្ធកាល ចំណែកសម័យកាលពីរខាងក្រោយ ជាហេតុការណ៍ដែលកើតឡើងក្រោយព្រះពុទ្ធបរិនិព្វាន ( ព្រះពុទ្ធបរិនិព្វានកាលពី ៥៤៣ ឆ្នាំមុនគ្រិស្តសករាជ) ។

ដើម្បីអោយមានពន្លឺក្នុងរឿងនេះតែច្បាស់ឡើង នឹងសូមបកស្រាយពីការប្រព្រឹត្តទៅទាក់ទងនឹងរបបប្រជាធិបតេយ្យរបស់ក្រិច ដែលកើតឡើងបន្តបន្ទាប់គ្នាទាំងបីសម័យកាល ដើម្បីនឹងបានយកមកប្រៀបធៀបជាមួយនឹងប្រព័ន្ធប្រជាធិបតេយ្យដែលព្រះសម្មាសម្ពុទ្ធបានទ្រង់ប្រទានទុកមក ។ ប៉ុន្តែគប្បីចាំអោយ

បានច្បាស់ថា ម្យ៉ាងជារឿងនយោបាយ ហើយម្យ៉ាងទៀតជារឿងសាសនា នឹងអោយដូចគ្នាទាំងស្រុងនោះមិនអាចទៅរួចទេ ដូច្នេះអ្វីដែលគួរយកមកពិចារណានោះគឺ គោលការណ៍។
សម័យដែលសូឡូនកែប្រែរដ្ឋធម្មនុញ្ញរបស់ក្រិចដែលជាហេតុអោយបានទទួលកិត្តិគុណថា ជាបិតាប្រជាធិបតេយ្យរបស់ក្រិចនោះ ជារបបមូលធននិយម ឬហៅថា រដ្ឋាភិបាលអភិជន (Aristocracy) គឺពួកជនវណ្ណៈខ្ពស់ជាអ្នកគ្រប់គ្រងអំណាចទូទៅ មានតែអ្នកកើតក្នុងវណ្ណៈអភិជនប៉ុណ្ណោះទើបអាចធ្វើជាថ្នាក់ដឹកនាំបាន ចំណែកអ្នកក្រីក្រលំបាកតោកយ៉ាកដែលជំពាក់បំណុល បើមិនអាចរកលុយមកដោះបំណុលបានទេត្រូវបាននាំខ្លួនទៅលក់អោយធ្វើជាខ្ញុំកញ្ជះគេ ទោះជាបំណុលនោះជួនកាលកើតឡើងពីការចាំបាច់ ដោយសារតែការប្រកបមុខរបរកសិកម្មមិនបានផលក៏ដោយ ។

សូឡូនជាអ្នកសំរេចចិត្តលុបបំបាត់ច្បាប់បំណុល ដោយមិនព្រមអោយម្ចាស់បំណុលយកកូនបំណុលទៅលក់ជាទាសករតទៅទៀត ។ យ៉ាងណាក៏ដោយ ការកែប្រែរដ្ឋធម្មនុញ្ញរបស់សូឡូន ក៏នៅតែបែងចែកវណ្ណៈរបស់មនុស្សជាបួនវណ្ណៈទៅតាមចំណូលដែលរកបាន ហើយមានតែអ្នកដែលរកចំណូលបានច្រើនប៉ុណ្ណោះទើបអាចមានចំណែកក្នុងការគ្រប់គ្រងប្រទេស។ អ្នករកចំណូលបានពីផលិតផលក្នុងមួយឆ្នាំ ៥០០ ប៊ុសុល [១] ឡើងទៅចាត់ជាមនុស្សវណ្ណៈទី១ (តែត្រូវកើតក្នុងត្រកូលខ្ពស់ផងដែរ) ។ អ្នកដែលរកចំណូលបានចាប់តាំងពីមួយឆ្នាំ ៣០០ ប៊ុសុលឡើងទៅចាត់ជាមនុស្សក្នុងវណ្ណៈទី២ ។ អ្នកដែលរកចំណូលបានពីផលិតផលតាំងពីមួយឆ្នាំ ២០០ ប៊ុសុលឡើងទៅចាត់ជាមនុស្សវណ្ណៈទី៣ ។ ចំណែកអ្នកដែលរកចំណូលបានទាបជាងនេះចាត់ជាមនុស្សក្នុងវណ្ណៈទី ៤ ។

មនុស្សទាំងបួនវណ្ណៈនេះ អ្នកដែលមានសិទ្ធិធ្វើជាថ្នាក់ដឹកនាំ ដោយត្រូវបានជ្រើសតាំងជាមន្ត្រីជាន់ខ្ពស់ (archon) មានតែមនុស្សវណ្ណៈទី១ ប៉ុណ្ណោះ ។ ចំណែកតំណែងទាបចុះមកទៀត មនុស្សត្រឹមតែ ៣ វណ្ណៈ ខាងលើប៉ុណ្ណោះដែលមានសិទ្ធិចូលបំរើការបាន ដោយពុំរាប់បញ្ចូលវណ្ណៈទី ៤ ទេ ។

១ រង្វាស់រង្វាល់អង់គ្លេស 1bushel = 35.24 liters

បានសេចក្តីថា ក្នុងសម័យរបស់សូឡុន ដែលអ្នកប្រវត្តិសាស្ត្រខ្លះលើកតំកើងថាជាបិតានៃប្រជាធិបតេយ្យរបស់ក្រិចនោះ អ្នកទីទ័លក្រក៏នៅតែត្រូវបានគេចាត់ទុកជាមនុស្សវណ្ណៈទាប ព្រមទាំងគ្មានសិទ្ធិចូលរួមចំណែកទទួលតំណែងណាមួយរបស់រដ្ឋឡើយ ។ ហេតុនេះទើបអ្នកប្រវត្តិសាស្ត្រខ្លះមិនចាត់ទុកថាសូឡុនជាបិតាប្រជាធិបតេយ្យ ព្រោះនៅមានឈ្មោះថា ជាអ្នកលើកតំកើងរដ្ឋាភិបាលអភិជនដដែល ។

ក្នុងសម័យជាមួយគ្នានេះព្រះសម្មាសម្ពុទ្ធ ទ្រង់បានបញ្ញត្តិព្រះវិន័យប្រគល់សិទ្ធិដល់ភិក្ខុសង្ឃអោយមានអំណាចក្នុងការគប់គ្រងគណៈសង្ឃមានសិទ្ធិជំទាស់ ពេលដែលមិនយល់ស្របក្នុងករណីណាមួយដោយគ្មានកំណត់ថាជាអ្នកកើតក្នុងត្រកូលខ្ពស់ឬទាប ។ ទោះជាកើតក្នុងត្រកូលស្តុកស្តម្ភឬក្រីក្រតោកយ៉ាកយ៉ាងណាក៏ដោយ អោយតែចូលមកបួសហើយក៏ត្រូវតែមានសិទ្ធិស្មើគ្នាទាំងអស់ ហើយត្រូវគោរពគ្នាតាមលំដាប់បួសមុនបួសក្រោយ ។ ព្រោះហេតុនោះ អស់លោកអ្នកអានទាំងឡាយ អាចសំរេចបានដោយខ្លួនឯងថា ប្រជាធិបតេយ្យដ៏មានចំណាស់របស់ក្រិចនៅជារបបរដ្ឋាភិបាលអភិជន ឬ ជាអភិជនាធិបតេយ្យនៅឡើយ តែប្រជាធិបតេយ្យរបស់ព្រះពុទ្ធសាសនាជាប្រជាធិបតេយ្យដែលពិតប្រាកដតាំងពីយូរយាណាស់មកហើយ គឺក្នុងសម័យប្រហាក់ប្រហែលគ្នានឹងសម័យរបស់សូឡុន ។

ក្នុងសម័យបន្ទាប់ពីសូឡុនជិត១០០ឆ្នាំ អ្នកប្រវត្តិសាស្ត្រ បានពិចារណាថា ជាសម័យដែលប្រជាធិបតេយ្យកើតរូបរាងឡើង ក្នុងលក្ខណៈគួរជាទីពេញចិត្តគឺសម័យរបស់ឃ្លិសថេនីស លោកឃ្លិសថេនីស ត្រូវគេលើកតំកើងថា ជាអ្នកបណ្តេញរបបអភិជនាធិបតេយ្យពីក្រុងអាសិនស៍ (Athens) ហើយបង្កើតលទ្ធិប្រជាធិបតេយ្យឡើង ។ ការកែប្រែរដ្ឋធម្មនុញ្ញដែលដែលឃ្លិសថេនីសបានធ្វើនោះ គឺបានផ្តល់សិទ្ធិក្នុងការបញ្ចេញសំលេង (right to vote) ដល់ប្រជាជនទាំង ១០ កុលសម្ព័ន្ធដែលមិនមែនជាទាសករ (សម័យនោះនៅមាន របបទាសករនៅឡើយ) ។ ការបញ្ចេញមតិក្នុងទីប្រជុំជនបានដោយសេរី មានកាន់តែច្រើនឡើងហើយដែលចាត់ជាប្រវត្តិសាស្ត្រដែលគួរអោយកត់សំគាល់មួយក្នុងសម័យនោះគឺ ឃ្លិសថេនីស បានបង្កើតលទ្ធិបព្វានីយកម្ម (ostracism) គឺការអោយប្រជាជនសរសេរនឹងសំបកគ្រំម្នាក់មួយៗ ដើម្បីបញ្ចេញសំលេងបោះឆ្នោតជាសម្ងាត់ សំលេងឆ្នោតសំបកគ្រំ អាចនិរទេសនរណាម្នាក់ក៏បានដែលយល់ថាមិនគួរសមអោយចាកចេញពីប្រទេសបាន ដោយប្រកាន់យកសំលេងមិនពេញចិត្តចំនួន១០០០សំលេង និរទេសបាន

១០ ឆ្នាំ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏មនុស្សថ្នាក់ដឹកនាំដែលតំរូវអោយមានក្នុងវណ្ណៈខ្ពស់នៅមានដដែល គ្រាន់តែថា អោយតែជាវណ្ណៈទី១ អោយមានសិទ្ធិជាមន្ត្រីជាន់ខ្ពស់ (archon) បានដោយមិនចាំបាច់កើតក្នុងត្រកូលខ្ពស់គឺត្រកូលអភិជនឡើយ គ្រាន់តែអាចរកចំណូលបានក្នុងមួយឆ្នាំលើសពី ៥០០ ប៊ុសុល អាចធ្វើជាមនុស្សក្នុងវណ្ណៈទី ១ បាន ។

លុះមកដល់យុគមាសរបស់ក្រិចដែលគេចាត់ទុកថា ប្រជាធិបតេយ្យចំរើនរុងរោចន៍ដ៏ខ្លាំងជាទីបំផុតនោះ គឺបន្ទាប់ពីសម័យឃ្លិសថេនិសមកជិតមួយរយឆ្នាំ ដែលជាសម័យរបស់ប៉េរិឃ្លីស មានសេចក្តីអធិប្បាយ ទុកមកថា ក្រុងអាសិនស៍ មានអាណាខេត្តតូច មានពលរដ្ឋតិចទើបអាចប្រើប្រាស់របបប្រជាធិបតេយ្យដោយផ្ទាល់ គឺមិនចាំបាច់ជ្រើសរើសអ្នកតំណាង ។ គ្រប់គ្នាមានសិទ្ធិចូលប្រជុំបញ្ចេញមតិសំរេចជោគវាសនាប្រទេសជាតិក្នុងការធ្វើសង្គ្រាមឬក្នុងរឿងផ្សេងៗទៀត តែវាជាការលំបាកដែលធ្វើអោយមនុស្សចូលប្រជុំក្នុងកិច្ចការប្រទេសជាតិអោយបានគ្រប់ៗគ្នា ព្រោះហេតុនោះទើបមានអ្នកចូលប្រជុំចំពោះតែអ្នកដែលមានចំណាប់អារម្មណ៍ប៉ុណ្ណោះ ។

សេចក្តដូចបានពោលមកនេះ បញ្ជាក់អោយឃើញថា របបប្រជាធិបតេយ្យរបស់ក្រិចនោះ ទើបតែកើតមានរូបរាងឡើងពិតប្រាកដក្នុងពេលក្រោយព្រះពុទ្ធបរិនិព្វានអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ចំណែកសម័យដែលរាប់បានថា ជាយុគតំណាលនឹងព្រះសម្មាសម្ពុទ្ធគឺសម័យរបស់សូឡូននោះ នៅជារបបអភិជនាធិបតេយ្យនៅឡើយ ។

ក្នុងទីនេះ នឹងនិយាយអំពីរបបប្រជាធិបតេយ្យដែលយើងអាចមើលឃើញក្នុងព្រះពុទ្ធសាសនា តាមភស្តុតាងដែលមានប្រាកដក្នុងវិន័យបិដក ដូចតទៅ:

សូមរលឹកសារជាថ្មីម្តងទៀតថា ពាក្យថា ព្រះពុទ្ធសាសនា ជាគំរូនៃលទ្ធិប្រជាធិបតេយ្យនោះ គឺសំដៅយកគោលការណ៍ធំៗ មិនបានសំដៅដល់សេចក្តីលំអិតផ្សេងៗ ដែលជាឧបន្ទាប់បន្សំនោះទេ ព្រោះសេចក្តីលំអិតបន្ទាប់បន្សំនោះ ទោះយ៉ាងណា ការគ្រប់គ្រងគណៈសង្ឃ ក៏ត្រូវមានលក្ខណៈពិសេសផ្ទាល់ខ្លួន ដូចគ្នានឹងការគ្រប់គ្រងប្រទេសជាតិ រមែងមានបញ្ហា ឬ លក្ខណៈពិសេសខុសៗគ្នា ពីផ្លូវសាសនាដូច្នោះដែរ ។

## ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានភាពជាធំដល់សង្ឃ

សម័យពីដើម កាលដែលព្រះពុទ្ធសាសនាប្រតិស្ថានឡើងថ្មីៗ ព្រះសម្មាសម្ពុទ្ធទ្រង់ជាអ្នកប្រទានឧបសម្បទា ឬទទួលមនុស្សអោយចូលលទ្ធិដោយព្រះអង្គឯង ក្រោយមកទ្រង់បានបំបែកអោយព្រះសាវ័កមួយអង្គៗនិមន្តទៅផ្សព្វផ្សាយសាសនាក្នុងទិសផ្សេងៗគ្នា ហើយជាអ្នកអនុមតិកិច្ចការផ្នែកឧបសម្បទាបានដោយមានពិធីកម្មត្រឹមតែ អោយឧបសម្បទាបេក្ខ អ្នកដែលសុំបួស បញ្ចេញវាចាដល់នូវព្រះរតនត្រ័យជាសរណៈ ប៉ុណ្ណឹងជាការស្រេច ។ ក្រោយមកទៀត ពិធីបំបួសបែបនេះក៏ឈប់ប្រើប្រាស់ចំពោះឧបសម្បទាកម្ម (ការបំបួសភិក្ខុ) តែនៅប្រើសំរាប់តែបព្វជ្ជាកម្ម (ការបំបួសសាមណេរ) ។ បន្ទាប់មកពេលដែលមានអ្នកចូលមកបួសក្នុងព្រះពុទ្ធសាសនាកាន់តែច្រើនឡើង រហូតដល់មានបញ្ហាគ្រប់គ្រងកើតឡើង ព្រះសម្មាសម្ពុទ្ធទ្រង់ឈប់ប្រទានឧបសម្បទាដោយព្រះអង្គឯង ព្រមទាំងទ្រង់ឈប់ផ្តល់អំណាចជាឯកជនដល់ព្រះសាវ័កទាំងឡាយ ។ ទ្រង់បញ្ញត្តិអោយមានឧបសម្បទាតាមបែបសង្ឃកម្មម្តង រាធព្រាហ្មណ៍ជាមនុស្ស ដំបូងបង្អស់[១] ដែលបានទទួលឧបសម្បទា។

កាលបើយើងប្រមូលរួបរួមការឧបសម្បទា ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានទុកមក យើងអាច បែងចែកបានជាបីតំណាក់កាលគឺ:

១-តំណាក់កាលដំបូង ទ្រង់អនុមតិផ្តល់ឧបសម្បទាដោយព្រះអង្គឯងផ្ទាល់ ដែលបាលីហៅថា "**ឯហិភិក្ខុឧបសម្បទា**" ប្រែថា ការបួសដែលសំរេចដោយកិច្ចដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ត្រឹមតែព្រះពុទ្ធដីកាថា **ចូរអ្នកក្លាយមកជាភិក្ខុចុះ** ។

២-តំណាក់កាលទី២ ទ្រង់អនុញ្ញាតអោយព្រះសាវ័កទាំងឡាយជាអ្នកអនុមតិការបំបួស[២] ដោយអោយកុលបុត្រដែលជាអ្នកសុំបួស បញ្ចេញវាចាដល់នូវព្រះរតនត្រ័យជាទីពឹងទីរលឹក ដែលហៅថា "**តិសរណាគមនូបសម្បទា**" ប្រែថា ការបួសដោយដល់នូវត្រៃសរណគមន៍ ។

---

១. វិន័យបិដក ភាគ៤

២ ព្រះសម្ពុទ្ធអនុញ្ញាតអោយបំបួសតែអ្នកសុំបួសប៉ុណ្ណោះ ភិក្ខុណាបំបួសអ្នកដែលមិនបានសុំបួសត្រូវអាបត្តិទុក្កដ . វិន័យបិដកភាគ ៤

៣-តំណាក់កាលចុងក្រោយដែលប្រើរហូតដល់បច្ចុប្បន្ននេះ គឺទ្រង់អនុញ្ញាតចំពោះសង្ឃប៉ុណ្ណោះ ដែលជាអ្នកអនុមតិការបំបួស ដែលហៅថា "**ញត្តិចតុត្ថកម្មឧបសម្បទា**" ប្រែថា ការបួសដែលត្រូវសូត្រប្រកាសដល់សង្ឃនូវ**ញត្តិ** ១ដង និង**កម្មវាចា** ៣ដងដដែល។ ជាគម្រប់៤ ដង ។ បានសេចក្តីថា សូត្រញត្តិ គឺ ប្រកាសប្រាប់ដល់សង្ឃថាមានអ្នកមកសុំបួស ១ដង ហើយសូត្រកម្មវាចា គឺសូត្រប្រកាសសុំយោបល់អំពីសង្ឃ ដោយបើកឱកាសអោយជំទាស់បានក្នុងករណីដែលយល់ថាមិនសមស្រប ឬមិនត្រឹមត្រូវតាមព្រះវិន័យ ចំនួន៣ដង រួមត្រូវជា៤ ដង។

# ការកំណត់ចំនួនសង្ឃ ៥ ប្រភេទ

ជារឿងគួរអោយចាប់អារម្មណ៍ ដែលព្រះអង្គទ្រង់ប្រគល់អំណាចជាធំដល់សង្ឃហើយ ទ្រង់កំណត់ចំនួនសង្ឃទៅតាមកិច្ចការនីមួយ។ ដែលត្រូវមានចំនួនភិក្ខុតិចច្រើនខុស។គ្នា ដូចមានតទៅនេះ:

១-ភក្ខុសង្ឃ ៤អង្គហៅថា **សង្ឃចតុវគ្គ** ធ្វើសង្ឃកម្មបានគ្រប់ប្រភេទ វៀរលែងតែការឧបសម្បទា ការបវារណាដែលជាពិធីកម្មថ្ងៃចេញវស្សា ដែលអនុញ្ញាតអោយពោលស្តីថាដាស់តឿនគ្នានិងគ្នាបាន និងការសូត្រអព្ភានកម្មគឺការសូត្រដោះគរុកាបត្តិ បានដល់អាបត្តិធ្ងន់របស់ភិក្ខុណាមួយ ដែលកំណត់អោយមានចំនួនភិក្ខុសង្ឃច្រើនជាងនោះ ។

២-ភិក្ខុសង្ឃ ៥អង្គហៅថា **សង្ឃបញ្ចវគ្គ** ធ្វើកិច្ចបវារណា ធ្វើឧបសម្បទាកម្មក្នុងបច្ចន្តជនបទ[១] និងធ្វើសង្ឃកម្មដទៃទៀតបានលើកលែងតែអព្ភានកម្ម និង ឧបសម្បទាកម្មក្នុងមជ្ឈិមជនបទ គឺជនបទភូមិភាគកណ្តាល ដែលមានសេចក្តីចំរើន គឺមានព្រះសង្ឃច្រើន។

៣-ភិក្ខុសង្ឃ ១០ អង្គហៅថា **សង្ឃទសវគ្គ** ធ្វើការឧបសម្បទា ក្នុងមជ្ឈិមជនបទ គឺជនបទភូមិភាគកណ្តាលនៃប្រទេសឥណ្ឌា ហើយនិងធ្វើសង្ឃកម្មដទៃទៀតបាន លើកលែងតែអព្ភានកម្មតែម៉្យាង ។

៤-ភិក្ខុសង្ឃ ២០ អង្គហៅថា **សង្ឃវីសតិវគ្គ** ដោយចោះចំពោះដើម្បីប្រើក្នុងការប្រជុំដោយមានភិក្ខុរូបណាមួយជាអ្នកសូត្រដកអាបត្តិធ្ងន់ របស់ភិក្ខុដែលត្រូវអាបត្តិ ។

---

១. បច្ចន្តជនបទ គឺជនបទជាយដែន ដែលមិនសំបូរព្រះសង្ឃ មជ្ឈិមជនបទ គឺជនបទភូមិភាគកណ្តាល ដែលសំបូរព្រះសង្ឃ

៥-ភិក្ខុសង្ឃលើសពី ២០ អង្គហៅថា **សង្ឃអតិរេកវីសតិវគ្គ** ធ្វើសង្ឃកម្មបានគ្រប់ប្រភេទ ។ លក្ខ័ន្តនៃការកំណត់ចំនួនដូចដែលបានពោលមកនេះ នៅត្រង់ថា កិច្ចការប្រភេទណា កំណត់ចំនួនទាបបំផុតរបស់សង្ឃត្រឹមប៉ុន្មានអង្គ សង្ឃលើសចំនួនអាចធ្វើបាន សង្ឃមានចំនួនតិចជាងចំនួនកំណត់ ធ្វើមិនបាន។ ព្រោះហេតុនោះ បើពោលម្យ៉ាងទៀត ដោយបញ្ជាក់ពីប្រភេទសង្ឃកម្មនីមួយៗថា សង្ឃកម្មបែបណាយកភិក្ខុសង្ឃប៉ុន្មានអង្គ ក៏អាចពោលបានដូចតទៅនេះ:

**១.ការធ្វើឧបោសថ** គឺការសូត្របាតិមោក្ខ ឬសូត្ររំលឹកសីលរបស់ភិក្ខុទាំង ២២៧ សិក្ខាបទ គ្រប់កន្លះខែម្តង ភិក្ខុសង្ឃចាប់តាំងពី៤ អង្គឡើងទៅអាចធ្វើបាន ។

**២.ការសូត្រសន្មតិផ្សេងៗ** ដូចជាសន្មតិឬតែងតាំង ភិក្ខុអ្នកចាត់ចែងការងាររបស់សង្ឃជាអ្នកចែកចីវរចែកសេនាសនៈ គឺទីស្នាក់អាស្រ័យ ភិក្ខុសង្ឃតាំងពី ៤ អង្គឡើងទៅអាចធ្វើបាន ។

**៣.ការសូត្រកឋិន** គឺសូត្រប្រកាសប្រគល់សំពត់កឋិនដល់ភិក្ខុអង្គណាមួយ ដោយសុំសេចក្តីយល់ព្រមពីព្រះសង្ឃទាំងឡាយ ភិក្ខុចាប់តាំងពី ៥ អង្គឡើងទៅអាចធ្វើបាន ។

**៤.ការបវារណា** គឺការប្រាប់អនុញ្ញាតអោយដាស់តឿនគ្នានិងគ្នា ជាកិច្ចរបស់សង្ឃ ភិក្ខុតាំងពី ៥ អង្គឡើងទៅទើបធ្វើបាន ទាំងនេះដោយមានហេតុផលថា បើចាត់ទុកភិក្ខុ៤ អង្គជាសង្ឃ បើមានភិក្ខុត្រឹមតែ ៤អង្គ ហើយអង្គណាមួយពោលបវារណាក៏ដូចជាអនុញ្ញាតដល់បុគ្គល៣អង្គអោយពោលដាស់តឿនបាន ។ ព្រះសម្មាសម្ពុទ្ធចាត់ទុកថាជាការបវារណាចំពោះបុគ្គល ។ កិច្ចដែលអាចចាត់ទុកថាជា សង្ឃកម្មបានលុះត្រាតែសង្ឃជាអ្នកស្តាប់ពាក្យបវារណាមាន ៤ អង្គ គម្រប់ ៥ អង្គទាំងភិក្ខុអ្នកបវារណា ឬចំនួនច្រើនជាងនោះទៀត ។

**៥.ការឧបសម្បទា ឬ ការបំបួសភិក្ខុ** បើក្នុងបច្ចន្តជនបទ គឺតំបន់ជាយដែន ឬតំបន់ដែលគ្មានសេចក្តីចំរើន ពិបាកក្នុងការរកព្រះសង្ឃ ដូច្នេះសង្ឃបញ្ចវគ្គគឺព្រះសង្ឃចាប់ពី ៥អង្គឡើងទៅ អាចធ្វើការបំបួសបាន ។ បើនៅក្នុងមជ្ឈិមជនបទ គឺតំបន់ភូមិភាគកណ្តាល ដែលមានកំណត់ដែនទុកក្នុងសម័ពុទ្ធកាលជាតំបន់ដែលរីកចំរើន មានព្រះសង្ឃច្រើន ព្រះអង្គទ្រង់អោយបំបួសកុលបុត្រដោយសង្ឃទសវគ្គ គឺព្រះសង្ឃចាប់ពី១០ អង្គឡើងទៅ ។

នៅក្នុងប្រទេសកម្ពុជាយើង ដែលជាតំបន់ក្រៅទីកំណត់ក្នុងសម័យពុទ្ធកាល ព្រះសង្ឃចាប់ពី ៥អង្គឡើងទៅអាចធ្វើឧបសម្បទាកម្ម គឺ ការបំបួសភិក្ខុបាន ។

**៦.ការសូត្រអព្ភាន** គឺការសូត្រដោះអាបត្តិរបស់ភិក្ខុអង្គណាមួយ ឬថា ជាការសូត្រប្រកាសសេចក្តីបរិសុទ្ធដើម្បីទាញត្រឡប់រាប់រកយកជាគ្នាវិញ ។ បានសេចក្តីថា ការដែលភិក្ខុសង្ឃមានចំនួនយ៉ាងតិចត្រឹម ២០ អង្គប្រជុំគ្នាក្នុងសីមា អោយភិក្ខុមួយអង្គសូត្រកម្មវាចាប្រកាសសេចក្តីចំពោះភិក្ខុដែលត្រូវអាបត្តិសង្ឃាទិសេស ហើយបាននៅបរិវាសនិងមានត្តអស់កាលកំណត់រាត្រីហើយ ដើម្បីរាប់រកភិក្ខុនោះយកជាគ្នា ទុកថាជាអ្នកបរិសុទ្ធដូចដើមវិញ ។

**៧.សង្ឃកម្មផ្សេងៗ** ដែលធ្វើជាកិច្ចការរបស់សង្ឃ ក្រៅពីកិច្ចដែលបានពោលមកហើយនេះ អាចធ្វើឡើងដោយភិក្ខុ៤ អង្គឡើងទៅបានទាំងអស់ ។

## ការកំណត់ទីកន្លែងប្រជុំ

ការធ្វើសង្ឃកម្មគឺកិច្ចការរបស់សង្ឃគ្រប់យ៉ាង ត្រូវមានការកំណត់ទីកន្លែងប្រជុំ ព្រំដែនដែលប្រើសំរាប់កំណត់ទីកន្លែងប្រជុំហៅថា **សីមា** ។ សីមា ឬដែនកំណត់ទីកន្លែងប្រជុំនេះមិនអោយតូចពេករហូតដល់ភិក្ខុ២១រូប អង្គុយមិនចុះ ហើយក៏មិនអោយធំហួសពី ៣ យោជន៍ [(១)] បើគិតពីចំនួនភិក្ខុសង្ឃ លោកថាត្រឹមភិក្ខុចំនួន ១០០០ អង្គអង្គុយចុះជាការសមល្មម ។

បើតូចហួសពេកក៏មិនអាចធ្វើសង្ឃកម្មដែលត្រូវមានភិក្ខុសង្ឃ២០អង្គ រួមជាមួយនឹងភិក្ខុដែលសុំអោយសង្ឃចំនួននោះប្រជុំដោះអាបត្តិអោយរួមជា២១ អង្គបាន ។ ព្រោះហេតុនោះទើបត្រូវកំនត់ទំហំមិនអោយតូចជាងនោះ ហើយទំហំដែលធំជាង ៣ យោជន៍ ក៏ពិបាកក្នុងការដែលសង្ឃមកចូលរួមប្រជុំព្រមគ្នា

---

១. មាត្រារង្វាស់បុរាណមានពីរយ៉ាងគឺ វាស់ចម្ងាយនិងវាស់កំពស់ ។ វាស់ចម្ងាយ ១ យោជន៏= ៤ គាវុធ= ៤០០ សិន= ៨០០០ ព្យាម= ១៦ គម ។ វាស់កំពស់ ដូចជាភ្នំឬដើមឈើជាដើម ១ យោជន៏= ៧ ហត្ថ = ៣.៥០ ម ។ យោជន៏ក្នុងទីនេះសំដៅយកចម្ងាយបីយោជន៏ជុំវិញ ។

ក្នុងកន្លែងដែលបានកំណត់ទុក ព្រមទាំងពិបាកក្នុងការត្រួតពិនិត្យថាអង្គណានិមន្តមក ហើយអង្គណាមិនបាននិមន្តមកខ្លះ ។

វត្ថុដែលយកជានិមិត្តសំរាប់កំណត់ដែនសីមានោះមាន ភ្នំ ថ្ម ព្រៃឈើ ដើមឈើដែលមានខ្លឹម ផ្លូវ ដំបូក ស្ទឹងឬទន្លេដែលទឹកហូរមិនដាច់ ស្រះឬថ្លុក ។

កិច្ចដែលត្រូវមានកំណត់ថា ទីប្រជុំត្រូវមានទំហំខ័ណ្ឌសីមាទំហំប៉ុណ្ណោះប៉ុណ្ណោះនោះ ក៏ដើម្បីអោយភិក្ខុគ្រប់អង្គដែលគង់នៅក្នុងសីមានោះ ដឹងពីតួនាទីរបស់ខ្លួនថា ពេលមានការប្រជុំម្តងៗ គ្រប់អង្គត្រូវចូលប្រជុំទាំងអស់ បើមិនចូលប្រជុំទេ កម្មនោះក៏មិនបានឈ្មោះថាជាសង្ឃកម្មឡើយ ហើយបើជាកម្មដែលមានបទបញ្ញត្តិអោយភិក្ខុគ្រប់អង្គត្រូវចូលប្រជុំផងនោះ អង្គដែលមិនចូលប្រជុំនឹងត្រូវអាបត្តិ ។

ក្នុងករណីដែលភិក្ខុនៅក្នុងខ័ណ្ឌសីមាដែលត្រូវប្រជុំនោះមានអាពាធ មិនអាចចូលប្រជុំបាន ត្រូវតែអោយឆន្ទៈ ទៅប្រកាសដល់សង្ឃដែលនៅក្នុងទីប្រជុំថា ភិក្ខុអង្គនេះ អង្គនោះនិមន្តមកមិនរួចព្រោះមានអាពាធ សុំអោយឆន្ទៈ[១] គឺអនុមតិអោយសង្ឃធ្វើការប្រជុំបានដោយសេចក្តីព្រមព្រៀង ទទួលដឹងឮនិងយល់ស្របតាមមតិយោបល់របស់ខ្លួន ។ បើទីប្រជុំនោះជាការប្រជុំស្តាប់បាដិមោក្ខ គឺសិក្ខាបទ ២២៧ របស់ភិក្ខុ បើភិក្ខុអង្គណាអាពាធត្រូវប្រាប់បារិសុទ្ធិ[២] គឺអោយភិក្ខុអង្គណាមួយទៅប្រកាសដល់សង្ឃថា ភិក្ខុអង្គដែលអាពាធនោះជាភិក្ខុបរិសុទ្ធិ ។ ការប្រាប់បារិសុទ្ធិនោះ បើទៅប្រាប់ដោយខ្លួនឯងបានក៏ទៅដោយខ្លួនឯង បើទៅមិនបានក៏ប្រាប់អោយភិក្ខុអង្គដទៃប្រាប់ជំនួស ។

ម្យ៉ាងទៀត ក្នុងពេលដែលកំពុងអង្គុយប្រជុំគ្នា ភិក្ខុរូបណាមួយមានកិច្ចចាំបាច់ដូចជា ធ្វើសរីរកិច្ចជាដើម មុននឹងក្រោកចេញពីទីប្រជុំត្រូវអោយឆន្ទៈជាមុនសិន គឺអនុញ្ញាតអោយសង្ឃធ្វើសង្ឃកម្មតទៅដោយការព្រមព្រៀងរបស់ខ្លួន បើមិនដូច្នោះទេ ភិក្ខុអង្គនោះនឹងត្រូវអាបត្តិ ។ ទាំងអស់នេះ គឺធ្វើឡើងដើម្បីមិនអោយមានការនិយាយឡើងបានក្នុងពេលក្រោយថា សង្ឃធ្វើសង្ឃកម្មដោយភិក្ខុអង្គនេះអង្គនោះមិនយល់ស្រប ។

---

១. ការយល់ព្រម

២. សេចក្តីបរិសុទ្ធ

កិច្ចដែលភិក្ខុអ្នកនៅក្នុងខ័ណ្ឌសីមា លុះដល់ពេលធ្វើសង្ឃកម្មដែលមានការកំណត់អោយភិក្ខុគ្រប់រូបខានមិនបាន ដូចជាស្តាប់បាដិមោក្ខ និង បវារណា ភិក្ខុអាចអវត្តមានបានចំពោះតែករណីអាពាធប៉ុណ្ណោះ កិច្ចការរវល់ដទៃៗមិនអាចយកមកជាសំអាងបានទេ ។ បើជាប់រវល់កិច្ចការផ្សេងៗនៅក្រៅខ័ណ្ឌសីមា មិនត្រូវអាបត្តិទេ តែប្រសិនបើបោះបង់តួនាទី គឺ កាលដែលគ្រប់១៥ថ្ងៃដែលនឹងត្រូវចូលប្រជុំស្តាប់បាដិមោក្ខ ឬ ធ្វើកិច្ចបវារណា ភិក្ខុរូបនោះបែរជាគេចវេសទៅនេះទៅនោះ ភិក្ខុនោះនឹងត្រូវអាបត្តិ ។

ក្នុងករណីដែលសង្ឃកម្មមិនមានការកំណត់ ដូចជា ឧបសម្បទាកម្ម កឋិនកម្ម ឬ ការប្រជុំដើម្បីតែងតាំងគណៈកម្មការសង្ឃ ភិក្ខុអង្គខ្លះអាចមិនចូលប្រជុំក៏បាន តែមិនត្រូវនៅក្នុងខ័ណ្ឌសីមាទេ បើនៅក្នុងខ័ណ្ឌសីមាហើយមិនចូលប្រជុំ កម្មនោះទុកជាមោឃៈ ឈ្មោះថាមិនបានធ្វើ ។

# សិទ្ធិរបស់ភិក្ខុអ្នកចូលប្រជុំ

ភិក្ខុគ្រប់រូបដែលចូលប្រជុំក្នុងកិច្ចការរបស់សង្ឃ មានសិទ្ធិបញ្ចេញមតិ ទាំងមតិជំទាស់និងមតិស្រប។ តាមប្រក្រតី ពេលដែលសួរនូវគំហើញរបស់ទីប្រជុំ បើយល់ស្របអោយប្រើវិធីស្ងៀមស្ងាត់ ឬហៅថាយល់ស្របដោយតុណ្ហីភាព បើភិក្ខុអង្គណាមិនយល់ស្រប អោយឡើងជំទាស់ ។ ក្នុងករណីដែលមានអ្នកជំទាស់ក៏ត្រូវមានការចរចា សម្រុះសម្រួលគ្នា រហូតដល់អ្នកជំទាស់នោះព្រមយល់ស្របតាម ប្រសិនបើភិក្ខុអ្នកជំទាស់នៅតែប្រកាន់យកគំនិតដើមរបស់ខ្លួន មិនយល់ស្របតាម ការឧបសម្បទាដែលជាការទទួលសមាជិកថ្មីចូលសង្ឃមណ្ឌលក្តី ការប្រគល់សំពត់កឋិនក្តី រមែងមិនបានបរិបូណ៌តាមការគួរ ព្រោះហេតុនោះមតិរបស់ទីប្រជុំត្រូវប្រកាន់យកមតិជាឯកច្ឆ័ន្ទ គឺភិក្ខុក្នុងទីប្រជុំត្រូវយល់ស្របគ្នាគ្រប់ៗអង្គ ។

ម្យ៉ាងទៀតគប្បីជ្រាបថា ការយកមតិជាឯកច្ឆន្ទ័នោះមិនមែនធ្វើទៅគ្រប់ករណីទាំងអស់នោះទេ ពោលគឺ បើមានមតិផ្ទុយគ្នាជាពីរពួក ក៏ត្រូវរកមធ្យោបាយដោះស្រាយដោយវិធីចាប់ឆ្នោត ធ្វើឡើងតាមការយកសំលេងភាគច្រើន ដើម្បីអោយដឹងថា សំលេងខាងណាច្រើនជាងខាងណា ហើយក៏សំរេចទៅតាមសំលេងភាគច្រើននោះ វិធីនេះហៅថា **យេភុយ្យសិកា** គឺយកសំលេងខាងច្រើនជាប្រមាណ ។

ដូចដែលបានបកស្រាយបរិយាយរាយរាប់សេចក្តីមកនេះ អស់លោកអ្នកអានទាំងឡាយក៏អាចសំលឹងឃើញលក្ខណៈប្រជាធិបតេយ្យនៃព្រះពុទ្ធសាសនាបានច្រើនតាមលំដាប់លំដោយ ។

សេចក្ដីជាបន្តទៅនេះ នឹងសូមបង្ហាញពីបែបបទគំរូ នៃការសូត្រប្រកាសផ្ដល់សិទ្ធិបញ្ចេញសំលេងដល់អ្នកចូលប្រជុំ ។ ការសូត្រប្រកាសចែកចេញជាពីរយ៉ាងគឺ

១-សូត្រញត្តិ គឺប្រកាសអោយសង្ឃបានដឹងឮ ១ដង

២-សូត្រកម្មវាចា គឺសុំមតិពីសង្ឃ ១ ដង

ហៅថា **ញត្តិទុតិយកម្ម** ប្រែថា សង្ឃកម្មដែលមានដែលមានកម្មវាចាមួយលើក ជាគំរប់ពីលើកនឹងញត្តិ គឺសង្ឃកម្មដែលមាន **ញត្តិ** មួយលើក **កម្មវាចា** មួយលើក ។

ម្យ៉ាងទៀត ការសូត្រប្រកាសអោយសង្ឃបានដឹង (ញត្តិ)១ដង សូត្រសុំមតិពីសង្ឃ(កម្មវាចា) ៣ដង ដដែល១ រួមត្រូវជា ៤ ដង ហៅថា **ញត្តិចតុត្ថកម្ម** ប្រែថា សង្ឃកម្មដែលសូត្រប្រកាសអោយសង្ឃបានដឹង (ញត្តិ) ១ដង និង សូត្រសុំមតិពីសង្ឃ (កម្មវាចា) ៣ដង រួមត្រូវជា ៤ ដង ។

ជាទូទៅ ការសូត្រប្រកាស ដែលសូត្រញត្តិ ១ដង និង កម្មវាចា ៣ដង ដែលហៅថា ញត្តិចតុត្ថកម្មនោះ លុះត្រាតែមានកិច្ចការសំខាន់ ដូចជា ការបំបួសកុលបុត្រ ការដាក់ទោសភិក្ខុដែលប្រព្រឹត្តខុស ៧ យ៉ាងមានតជ្ជនីយកម្ម[១] ជាដើម ការលើកលែងទោសពេលភិក្ខុនោះកែខ្លួនជាមនុស្សល្អវិញ ការសូត្រសន្មតគឺតែងតាំងភិក្ខុអោយជាអ្នកប្រដៅនាងភិក្ខុនី ហើយនឹងកិច្ចការដទៃ១ទៀត ។ ដែលត្រូវមានការសូត្រសុំមតិដដែល១រហូតដល់ ៣ ដង ក៏ដើម្បីអោយមានពេលពិចារណាអោយបានល្អិតល្អន់ ។ ចំណែករឿងដែលមានសារៈសំខាន់តិចជាងនេះ គ្រាន់តែសូត្រញត្តិម្ដង និង កម្មវាចា ម្ដងក៏ជាការគ្រប់គ្រាន់ទៅហើយ ។

# បែបបទនៃការសូត្រសុំមតិយល់ស្រប

# ដែលមាន ញត្តិ ១ដង និង កម្មវាចា ១ដង

# ហៅថា ញត្តិទុតិយកម្ម

១ ការរិះគន់ស្ដីប្រដៅ ២ ឈ្មោះភិក្ខុអ្នកក្រាលគ្រង

## ចំពោះការប្រគល់សំពត់កឋិនកឋិន

បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សំពត់កឋិននេះកើតឡើងដល់សង្ឃហើយ ។ បើ (ការនេះ) មានកាលគួរដល់សង្ឃហើយ សង្ឃគួរឱ្យសំពត់កឋិននេះ ទៅភិក្ខុ(ឈ្មោះនេះ[១]) ដើម្បីក្រាលកឋិន ។ នេះជាពាក្យផ្ទៀង (ញត្តិ) ។

បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សំពត់កឋិននេះកើតឡើងដល់សង្ឃហើយ ។(ឥឡូវ) សង្ឃអោយសំពត់កឋិននេះទៅភិក្ខុ(ឈ្មោះនេះ) ដើម្បីក្រាលកឋិន ។ ការដែលអោយសំពត់កឋិននេះ (ទៅភិក្ខុឈ្មោះនេះ) ដើម្បីក្រាលកឋិន គួរដល់លោកមានអាយុអង្គណាលោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង ។ សំពត់កឋិននេះ សង្ឃអោយទៅភិក្ខុ(ឈ្មោះនេះ) ហើយ ដើម្បីក្រាលកឋិន ។

(ការនេះ) គួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវការនេះដោយភាពដែលសង្ឃស្ងៀមយ៉ាងនេះ ។

## បែបបទនៃការសូត្រសុំមតិយល់ស្រប

## ដែលមាន ញត្តិ ១ដង និង កម្មវាចា ៣ដង

## ញត្តិចតុត្ថកម្ម

## ចំពោះការបំបួសកុលបុត្រ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតឧបសម្បទាបេក្ខៈ[២] ឈ្មោះនាគនេះ (ជាសទ្ធិវិហារិក[២]) នៃព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាអ្នកសំលឹងយកនូវឧបសម្បទា បរិសុទ្ធផុតចាកអន្តរាយិកធម៌[៣] ទាំងឡាយហើយ បាត្រនិងចីវររបស់ (ឧបសម្បទាបេក្ខៈឈ្មោះនាគ) មានគ្រប់គ្រាន់ហើយ

---

២ កុលបុត្រដែលត្រូវបំបួស ២ សិស្ស ៣ ធម៌ដែលធ្វើអោយអន្តរាយ ធម៌ទំនាស់នឹងវិនយប្បញ្ញត្តិដែលមិនអាចអោយកុលបុត្របួសបាន

ឧបសម្បទាបេក្ខៈឈ្មោះនាគ មានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាព្រះឧបជ្ឈាយ៍មកសូមនូវឧបសម្បទានឹងព្រះសង្ឃ បើ(ឧបសម្បទាកម្មនេះ) មានកាលដ៏សមគួរដល់ព្រះសង្ឃហើយ ព្រះសង្ឃគប្បីញុំាងឧបសម្បទា បេក្ខៈឈ្មោះនាគ មានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាព្រះឧបជ្ឈាយ៍ អោយបាននូវឧបសម្បទា វាចានេះជាវាចាសំរាប់ញុំាងសង្ឃអោយដឹង (ញត្តិ) ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតឧបសម្បទាបេក្ខៈ[១] ឈ្មោះនាគនេះ (ជាសទ្ធិវិហារិក) នៃព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាអ្នកសំលឹងយកនូវឧបសម្បទា បរិសុទ្ធផុតចាកអន្តរាយិកធម៌[៣] ទាំងឡាយហើយ បាតនិងចីវររបស់ (ឧបសម្បទាបេក្ខៈឈ្មោះនាគ) មានគ្រប់គ្រាន់ហើយ ឧបសម្បទាបេក្ខៈឈ្មោះនាគមានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុជាព្រះឧបជ្ឈាយ៍មកសូមនូវឧបសម្បទានឹង ព្រះសង្ឃ ព្រះសង្ឃក៏បានញុំាងឧបសម្បទាបេក្ខៈឈ្មោះនាគ មានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុជាព្រះឧបជ្ឈាយ៍ អោយបាននូវឧបសម្បទា ការដែលអោយនូវឧបសម្បទាដល់ឧបសម្បទាបេក្ខៈឈ្មោះនាគមានព្រះថេរៈឈ្មោះ តិស្សៈដ៏មានអាយុជាព្រះឧបជ្ឈាយ៍ (នេះ) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម បើមិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ខ្ញុំព្រះករុណា ពោលនូវសេចក្តីនេះជាគម្រប់ ២ដងផង ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតឧបសម្បទាបេក្ខៈឈ្មោះនាគនេះ (ជាសទ្ធិវិហារិក) នៃព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាអ្នកសំលឹងយកនូវឧបសម្បទាបរិសុទ្ធផុតចាក អន្តរាយិកធម៌ទាំងឡាយហើយ បាតនិងចីវររបស់ (ឧបសម្បទាបេក្ខៈឈ្មោះនាគ) មានគ្រប់គ្រាន់ហើយ ឧបសម្បទាបេក្ខៈឈ្មោះនាគមានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុជាព្រះឧបជ្ឈាយ៍មកសូមនូវឧបសម្បទា នឹង ព្រះសង្ឃ ព្រះសង្ឃក៏បានញុំាងឧបសម្បទាបេក្ខៈឈ្មោះនាគ មានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុជាព្រះឧបជ្ឈាយ៍ អោយបាននូវឧបសម្បទា ការដែលអោយនូវឧបសម្បទាដល់ឧបសម្បទាបេក្ខៈឈ្មោះនាគមានព្រះថេរៈឈ្មោះ តិស្សៈដ៏មានអាយុជាព្រះឧបជ្ឈាយ៍ (នេះ) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏

មានអាយុអង្គនោះគប្បីស្ងៀម បើមិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ខ្ញុំព្រះករុណា ពោលនូវសេចក្តីនេះជាគម្រប់ ៣ដងផង ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ។ល។ គួរដល់លោកដ៏មាន អាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម បើមិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។

ឧបសម្បទាបេក្ខៈឈ្មោះនាគ(នេះ) មានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាព្រះឧបជ្ឈាយ៍ គឺការកសង្ឃ[១] ឱ្យបានឧបសម្បទាហើយ (ការដែលអោយនូវឧបសម្បទា ដល់ឧបសម្បទាបេក្ខៈឈ្មោះនាគនេះ) ជាការគួរដល់ព្រះសង្ឃ ព្រោះហេតុនោះបានជាព្រះសង្ឃនៅស្ងៀម ខ្ញុំព្រះករុណា សូមចាំទុកនូវសេចក្តីនេះដោយអាការៈស្ងៀមដូច្នេះឯង ។

# មតិជំទាស់ស្តីពីលទ្ធិប្រជាធិបតេយ្យដ៏មានចំណាស់ជាងគេ

បើមានពាក្យជំទាស់ថា ការនិយាយថា ព្រះពុទ្ធសាសនាជាគំរូលទ្ធិប្រជាធិបតេយ្យដែលចាស់ជាងគេលើលោកនោះ សូមជំទាស់តាមប្រវត្តិសាស្ត្រដែលថា ក្នុងសម័យពុទ្ធកាលនោះឯង មានលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសឥណ្ឌាតាំងពីមុនស្រាប់ យើងអាចដឹងបានតាមការគ្រប់គ្រងរបស់ដែនវជ្ជី ដែលមានរាជធានីឈ្មោះថាក្រុងវេសាលីនោះ មានលិច្ឆវីសភាគឺ សភារបស់ស្តេចលិច្ឆវី មានការប្រជុំបែបសភាតំណាងរាស្ត្រដូចគ្នា ឬការគ្រប់គ្រងរបស់មល្លក្សត្រក្រុងកុសិនារា និង ក្រុងបាវ៉ា ក៏ប្រព្រឹត្តទៅក្នុងទ្រង់ទ្រាយមានសភាប្រជុំស្តាប់សំលេងភាគច្រើនដូចគ្នា ។កាលបើដូច្នេះហើយ នឹងពោលថា ព្រះពុទ្ធសាសនាជាគំរូនៃលទ្ធិប្រជាធិបតេយ្យដ៏មានចំណាស់ជាងគេម្តេចនឹងកើត ?

សូមឆ្លើយថា ការគ្រប់គ្រងរបស់ស្តេចលិច្ឆវី និងមល្លក្សត្រទាំងអស់នោះ មិនមែនការគ្រប់គ្រងបែបលទ្ធិប្រជាធិបតេយ្យទេ ជាការគ្រប់គ្រងបែបអភិជនាធិបតេយ្យ (Aristocracy) គឺមានពួកវណ្ណៈខ្ពស់ជាធំដោយប្រកាន់ដាច់ខាតថា ត្រូវតែជាក្សត្ររាជវង្សលច្ឆវី និង វង្សមល្លក្សត្រប៉ុណ្ណោះដែលជាអ្នកមានសិទ្ធិ

---

១ ព្រះសង្ឃដែលគង់ជាសាក្សី ព្រះសង្ឃគង់ហត្ថបាស

ចំណែកប្រជាជនទូទៅមិនមានចំណែកជាអ្នកមានសំលេងក្នុងសភានោះទេ ។ សូម្បីប្រវត្តិលទ្ធិប្រជាធិបតេយ្យក្នុងយុគមាសរបស់ក្រិចតាមការស្រាវជ្រាវពីប្រវត្តិពីប្រវត្តិរបស់អ្នកប្រាជ្ញសំខាន់ៗដូចជា Socrates, Plato ហើយនិង Aristotle ក៏ជាសម័យក្រោយពុទ្ធបរិនិព្វាន ពោលគឺ ព្រះសម្មាសម្ពុទ្ធបរិនិព្វានមុន Socrates កើតប្រហែល ៧៥ ឆ្នាំ មុន Plato កើតប្រហែល ១១៥ ឆ្នាំ ហើយនិងមុន Aristotle កើតប្រហែល ១៥៩ ឆ្នាំ ។ ហើយប្រជាធិបតេយ្យដែលពេញលេញ ដែលកើតឡើងចំពោះជនជាតិក្រិចនោះ តើមានវិសាលភាពប៉ុណ្ណា? យើងអាចពិចារណារកឃើញចាកការដែល Socrates ត្រូវគេបញ្ជាអោយសំលាប់ ខ្លួនដោយថ្នាំពុល ដោយសេចក្តីសំរេចដូចតទៅនេះ :

"Socrates ជាអ្នកមានទោសក្នុងបទឧក្រិដ្ឋ គឺ ប្រការដំបូង ព្រោះមិនបូជាទេវតាទាំងឡាយដែលមនុស្សទូទាំងប្រទេសគេបូជា បែរជាណែនាំអោយស្គាល់ទេវតាដទៃរបស់ខ្លួន ប្រការបន្ទាប់ ក៏ព្រោះធ្វើអោយពួកយុវវ័យបាត់បង់ជំនឿ ទោសដែលត្រូវទទួលគឺ សេចក្តីស្លាប់" (មើលសៀវភៅ Great Philosophers ទំព័រទី ៧ និង New Popular Encyclopaedia ភាគទី ១៣ ទំព័រ១៨២ )

ដោយមើលតាមភស្តុតាងផ្សេងៗទាំងអស់នេះបញ្ជាក់ថា ក្នុងពេលដែលព្រះភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនាកំពុងតែបានទទួលសិទ្ធិក្នុងការបញ្ចេញសំលេងក្នុងទីប្រជុំដោយគ្មានប្រកាន់វណ្ណៈ មិនប្រកាន់យសសក្តិតូចធំនោះ ប្រជាធិបតេយ្យរបស់ក្រិចបានសំលាប់មនុស្សដ៏សំខាន់ក្នុងលោកម្នាក់ដែលបានបញ្ចេញនូវគំហើញរបស់ខ្លួនដោយសេរី ។

ហេតុនេះ សូមអស់លោកអ្នកអានទាំងអស់វិភាគសាច់រឿងទាំងនេះដោយខ្លួនឯងចុះថា គោលការណ៍ប្រជាធិបតេយ្យដែលមានមកក្នុងព្រះពុទ្ធសាសនានោះ មានលក្ខណៈពិសេសដែលគួរចាប់អារម្មណ៍ដូចម្តេចខ្លះ ។

**ថ្ងៃទី ២៨ ខែ មករា ព.ស ២៥៤៩ គ.ស ២០០៦**